## ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាជាតិ វាយតម្លៃទទួលស្គាល់លើកដំបូង នៅទីស្តីការក្រសួងឧស្សាហកម្ម និងសិប្បកម្ម



នារសៀលថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០១៥ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងជាប្រធានក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់ បានអញ្ជើញជាអធិបតី ក្នុងការដឹកនាំកិច្ចប្រជុំ កិច្ចប្រជុំក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់ (Cambodia Accreditation National Council {CANC}) លើកដំបូង នៅទីស្តីការក្រសួងឧស្សាហកម្មនិងសិប្បកម្ម ។ ក្នុងកិច្ចប្រជុំនេះ មានការអញ្ជើញចូលរួមពីឯកឧត្តម អស់លោក ជាតំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសុខាភិបាល ក្រសួងពាណិជ្ជកម្ម ដែលជាអនុប្រធានក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់ ព្រមទាំងអស់លោក ជាតំណាងក្រសួង ស្ថាប័នរដ្ឋ និងវិស័យជាសមាជិក សរុបចំនួន៣០រូប ។





គួរបញ្ជាក់ថា៖អនុលោមតាមស្តង់ដារអន្តរជាតិនានា ជាពិសេសស្តង់ដារអន្តរជាតិ ISO/IES17011 ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានអនុញ្ញាតឱ្យនាយកដ្ឋានវាយតម្លៃទទួលស្គាល់ដំណើរការ និងសម្រេចចិត្តលើវិស័យតម្លៃទទួលស្គាល់ដោយឯករាជ្យ និងមិនលំអៀង ហេតុនេះទើបក្រសួងបាន បង្កើតឡើងនូវក្រុមប្រឹក្សាវាយតម្លៃទទួលស្គាល់ ដែលមាននាយកដ្ឋានវាយតម្លៃទទួលស្គាល់ជាសេនាធិការ ។

មានប្រសាសន៍បើកកិច្ចប្រជុំនាឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានបញ្ជាក់ថា៖ការងារវាយតម្លៃទទួលស្គាល់ ជាការងារមួយមានសារៈសំខាន់ និងស្មុគស្មាញ ដែលមានទំនាក់ទំនងគ្នាជាប្រព័ន្ធរវាងថ្នាក់អន្តរជាតិ ថ្នាក់តំបន់ ថ្នាក់សហគមន៍ ថ្នាក់ជាតិ ដែលនេះជាតម្រូវការចាំបាច់នៃអង្គការពាណិជ្ជកម្មពិភពលោក WTO ក្នុងន័យជួយគាំទ្រដល់កិច្ចការពាណិជ្ជកម្មពិភពលោក ក្នុងគោលបំណងកាត់បន្ថយបែបបទ និងការចំណាយផ្សេងៗ ដូចជា ការកាត់បន្ថយរបាំងបច្ចេកទេសលើការធ្វើពាណិជ្ជកម្ម កាត់បន្ថយនូវការចំណាយលើការធ្វើធុរកិច្ច ក៏ដូចជាវិស័យឧស្សាហកម្ម សំដៅធានាដល់អ្នកប្រើប្រាស់ ក្នុង និងក្រៅប្រទេស ដើម្បីទទួលបាននូវផលិតផល និងទំនិញមានគុណភាព សុវត្ថិភាព និងផាសុខភាព ។

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានខិតខំជម្រុញការងារវាយតម្លៃទទួលស្គាល់នេះឱ្យដំណើរការបានលឿន ដើម្បីត្រៀមចូលរួមអនុវត្តការធ្វើសមាហរណកម្មចូលក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាននៅចុងឆ្នាំ២០១៥ ខាងមុខនេះ ។ ជាលទ្ធផល កន្លងមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានខិតខំប្រឹងប្រែងរៀបចំលិខិតបទដ្ឋានគតិយុត្តិ រចនាសម្ព័ន្ធការងារវាយតម្លៃទទួលស្គាល់អនុលោមតាមស្តង់ដារអន្តរជាតិ ជាពិសេសស្តង់ដារ ISO/IEC 17011 ដែលក្នុងនោះរចនាសម្ព័ន្ធដឹកនាំ និងការអនុវត្តការងាររបស់នាយកដ្ឋានវាយតម្លៃទទួលស្គាល់ត្រូវដំណើរការដោយឯករាជ្យ គ្មានលម្អៀង តម្លាភាព និងមិនមានការមន្ទិលទាំងឡាយ (Conflict of Interest) នៅក្នុងរចនាសម្ព័ន្ធអនុវត្តការងារឡើយ ដោយក្រសួងបានពិនិត្យ និងរៀបចំរចនាសម្ព័ន្ធការងារ ដើម្បីឱ្យនាយកដ្ឋានវាយតម្លៃទទួលស្គាល់ដំណើរការសកម្មភាពខ្លួនស្របតាមស្ថានភាព ក្នុងអាស៊ាន និងអនុលោមតាមស្តង់ដារ ISO/IEC17011 ដែលបច្ចុប្បន្ននេះ ក្រសួងបានបង្កើតក្រុមប្រឹក្សា ជាតិវាយតម្លៃទទួលស្គាល់ ជាស្ថាប័នកំពូល ដើម្បីដឹកនាំការងារវាយតម្លៃទទួលស្គាល់ ដែលមានសមាជិកពីស្ថាប័នទាក់ទិនរបស់រាជរដ្ឋាភិបាល

ស្ថាប័នមិនមែនរដ្ឋាភិបាល និងតំណាងក្រុមហ៊ុនឯកជន ដែលមានឯកឧត្តមផ្ទាល់ឈរជាប្រធាន និងអនុប្រធានចំនួន ០៤រូប មកពីក្រសួងឧស្សាហកម្មនិងសិប្បកម្ម ០១ រូប ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ០១រូប ក្រសួងសុខាភិបាល០១រូប និងក្រសួងពាណិជ្ជកម្ម ០១រូប រួមទាំងសមាជិក ដែលសរុបមានចំនួន២០រូប ដើម្បីរួមគ្នាពិភាក្សាផ្តល់យោបល់លើផែនការយុទ្ធសាស្ត្រ គោលនយោបាយ ក៏ដូចជាលិខិតបទដ្ឋានគតិយុត្តិនានាចាំបាច់សម្រាប់ការងារវាយ តម្លៃទទួលស្គាល់នេះឱ្យបានដំណើរការលឿន និងរលូនដូចបណ្តាប្រទេសដ៏ទៃលើពិភពលោក ។

ការអនុវត្តកិច្ចដំណើរការការងារវាយតម្លៃទទួលស្គាល់តម្រូវឱ្យនាយកដ្ឋានវាយតម្លៃទទួលស្គាល់ ជាថ្នាក់សម្រេចចិត្តលើរាល់ការងារវាយតម្លៃទទួលស្គាល់ ជាស្ថាប័នមួយឯករាជ្យ និងមិនលម្អៀងដឹកនាំដោយ CANC ដែល CANC ជាស្ថាប័នមួយដំណើរការងាររបស់ខ្លួនដើម្បីធានាលើការងារចាំបាច់ដូចជាៈ–ពិភាក្សា និងផ្តល់យោបល់អំពីគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ ក្នុងការអនុវត្តការងារវាយតម្លៃទទួលស្គាល់ របស់នាយកដ្ឋានវាយតម្លៃទទួលស្គាល់ ដើម្បីដាក់ជូនរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ពិនិត្យ និងសម្រេច–ពិភាក្សា និងផ្តល់យោបល់អំពីកម្មវិធីការងារ គម្រោងថវិកាប្រចាំឆ្នាំ និងរបាយការណ៍ប្រចាំឆ្នាំ របស់នាយកដ្ឋានវាយតម្លៃទទួលស្គាល់ ដើម្បីស្នើសុំការយល់ព្រមពីក្រសួង–ពិនិត្យមើលរចនាសម្ព័ន្ធ បែបបទ និងនីតិវិធី ដែលរៀបចំឡើងដោយនាយកដ្ឋានវាយតម្លៃទទួលស្គាល់–ពិនិត្យតាមដាននូវរាល់កិច្ចដំណើរការរបស់នាយកដ្ឋានវាយតម្លៃទទួលស្គាល់ សំដៅធានាអះអាងចំពោះមុខក្រសួងស្ថាប័នពាក់ព័ន្ធ និងអង្គការអន្តរជាតិនានា នូវរាល់ដំណើរការ និងការសម្រេចចិត្តនានារបស់នាយកដ្ឋាន ប្រព្រឹត្តិទៅដោយឯករាជ្យ និងមិនលំអៀង ទៅតាមលិខិតបទដ្ឋានគតិយុត្តិ ដែលមានជាធរមាន និងអនុលោមតាមស្តង់ដារជាតិ និងអន្តរជាតិ–បង្កើតគណៈកម្មការដោះស្រាយរាល់ការតវ៉ា ដោយអង្គភាពវាយតម្លៃភាពអនុលោម រឺអ្នកប្រើប្រាស់លើការសម្រេចចិត្តរបស់ប្រធាននាយកដ្ឋានវាយតម្លៃទទួលស្គាល់–ធានាគុណភាព ប្រសិទ្ធិភាព តម្លាភាព នៃលទ្ធផលបំពេញការងារចុះបញ្ជីវាយតម្លៃទទួលស្គាល់ និងការងារវាយតម្លៃទទួលស្គាល់–បង្កើតនូវភាពជឿជាក់ និងទំនុកចិត្តដល់ភាគីពាក់ព័ន្ធលើសមត្ថភាពអង្គភាពវាយតម្លៃភាពអនុលោមគ្រប់កំរិតខ្នាត ដើម្បីឱ្យអ្នកប្រើប្រាសទទួលបាននូវផលិតផល រឺទំនិញ មានគុណភាព សុវត្ថិភាព និងផាសុខភាព ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បាននំរលឹកថាៈកាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៥ កន្លងទៅនេះ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីសម្តេចតេជោនាយករដ្ឋមន្ត្រី ឱ្យចុះហត្ថលេខាលើអនុសសារណៈយោគយល់ ជាមួយក្រសួងឧស្សាហកម្មថៃ លើកិច្ចសហប្រតិបត្តិការការងារវាយតម្លៃទទួលស្គាល់ និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានអនុញ្ញាតឱ្យនាយកដ្ឋានវាយតម្លៃទទួលស្គាល់ ចុះហត្ថលេខាជាមួយការិយាល័យក្រុមប្រឹក្សាស្តង់ដារជាតិថៃ លើ Technical Arrangement (TA) ដើម្បីអនុវត្តការងារវាយតម្លៃទទួលស្គាល់ ស្របតាមខ្លឹមសារនៃអនុស្សារណៈយោគយល់គ្នា និងគម្រោង ASEAN-PTB ដែលកំពុងអនុវត្តលើប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ។

កិច្ចប្រជុំថ្ងៃនេះ ពិតជាមានសារៈសំខាន់ណាស់ និងចាត់ទុកជាកិច្ចចាប់ផ្តើមដំណើរការការងារវាយតម្លៃទទួលស្គាល់លើកដំបូងនៅកម្ពុជា ដែលមិនបានធ្លាប់អនុវត្តពីមុនមក ។ ឯកឧត្តម សង្ឃឹមថាៈ តាមរយៈការពិភាក្សា និងផ្តល់

យោបល់ពីតំណាងស្ថាប័នពាក់ព័ន្ធ នឹងជួយឱ្យកិច្ចដំណើរការការងារវាយតម្លៃទទួលស្គាល់ប្រព្រឹត្តិទៅដោយរលូន និងទទួលបានជោគជ័យ ក្នុងគោលបំណងដើម្បីគ្រប់គ្រងទំនិញនាំចូល ដើម្បីឱ្យប្រជាជនយើងទទួលបាននូវទំនិញប្រកបដោយគុណភាព សុវត្ថិភាព និងសុខភាព ។ ម្យ៉ាងវិញទៀតកិច្ចដំណើការការងារវាយតម្លៃទទួលស្គាល់នៅពេលនេះ មានសារៈសំខាន់ណាស់ក្នុងការគាំទ្រដល់ផលិតផលទាំងអស់ក្នុងប្រទេសកម្ពុជា ដើម្បីនាំចេញទៅកាន់ទីផ្សារអាស៊ាន ក៏ដូចជាទីផ្សារពិភពលោកផងដែរ ។ ក្នុងន័យឱ្យលទ្ធផលពិសោធន៍មួយ រឺទំនិញមួយធ្វើចរាចរ ក្នុងទីផ្សារ និងទទួលស្គាល់ទៅវិញទៅមកគ្រប់ទីកន្លែង ព្រមទាំងចូលរួមចំណែកជួយជម្រុញការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជាឱ្យទទួលបានជោគជ័យ ។

បន្ទាប់មកអង្គពិធីតាមរបៀបវីរៈរបស់ខ្លួន គឺៈ-ការណែនាំខ្លួន ពីឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាសមាជិកក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់ -បទបង្ហាញពីលទ្ធផលការងារ និងផែនការសកម្មភាពរបស់នាយកដ្ឋានវាយតម្លៃទទួលស្គាល់ និងបទបង្ហាញពីការរៀបចំធ្វើពង្រាងច្បាប់ស្ដីពីការវាយតម្លៃទទួលស្គាល់ជាតិកម្ពុជា ដោយលោក ជៀន សេងគង់ ប្រធាននាយកដ្ឋានវាយតម្លៃទទួលស្គាល់នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។ ជាមួយគ្នានេះក៏មានបើកឱ្យមានការពិភាក្សា សំណួរ-ចម្លើយ ផងដែរ